UNITED NATIONS
CAMBODIA OFFICE OF THE
HIGH COMMISSIONER FOR HUMAN RIGHTS

NATIONS UNIES
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

Special Representative of the Secretary-General
for Human Rights in Cambodia
តំណាងពិសេសរបស់លោកអគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

COHCHR

# លោកតំណាងពិសេសរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុក សិទ្ធិមនុស្សប្រចាំកម្ពុជា

# ការបោះឆ្នោតក្រុមប្រឹក្សាឃុំ ឆ្នាំ២០០២

(១ ខែមករា ឆ្នាំ២០០១ ដល់ថ្ងៃទី១១ ខែមករា ឆ្នាំ២០០២-មុនយុទ្ធនាការឃោសនាបោះឆ្នោត)

របាយការណ៍នេះ ត្រូវបានរៀបចំចងក្រងឡើង ដោយលោកតំណាងពិសេសរបស់លោកអគ្គលេខាធិការ អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ដោយឈរលើមូលដ្ឋាននៃពតិមានដែលបាន ផ្តល់ដល់ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា។ របាយការណ៍នេះពិនិត្យមើល លើឧក្រិដ្ឋកម្ម និងការបភិតបំភ័យទាក់ទងនឹងការបោះឆ្នោត ដែលបានរំលោភលើច្បាប់ជាតិ និងបទដ្ឋាន សិទ្ធិមនុស្សអន្តរជាតិ ដែលការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជាបានដឹង ចាប់តាំង ពីថ្ងៃទី០១ ខែ មករា ឆ្នាំ២០០១ មក។ គោលបំណងជាបឋមនៃរបាយការណ៍នេះ គឺត្រូវផ្តល់ដល់រាជ រដ្ឋាភិបាលកម្ពុជានូវពតិមានស្តីពីករណីបែបនេះ និងផ្តល់ជាអនុសាសន៍នូវវិធីសាស្ត្រដើម្បីដោះស្រាយ ។

លោកតំណាងពិសេស សូមស្វាគមន៍ចំពោះការប្តេជ្ញាចិត្ត ដែលសម្តេចនាយករដ្ឋមន្ត្រីបានធ្វើឡើងនៅក្នុង សន្ទរកថារបស់សម្តេចកាលពីថ្ងៃទី១០ ខែធ្នូ ដែលជាទិវាសិទ្ធិមនុស្សអន្តរជាតិ ដើម្បីទប់ស្កាត់គ្រប់រូបភាព នៃអំពើហិង្សា និងការបំភិតបំភ័យ មុន ក្រោយ និងក្នុងអំឡុងពេលនៃការបោះឆ្នោត ។ ប៉ុន្តែ ការកើនឡើង នៃការស្លាប់ដែលទាក់ទងនឹងការបោះឆ្នោតថ្មីៗនេះ និងការកើតឡើងនៃគំរូដ៏ច្បាស់នៃ ការបំភិតបំភ័យ និងការរំខាននៅក្នុងតំបន់ជាច្រើននៃប្រទេស គឺជាព្រួយបារម្ភកាន់តែច្រើនឡើង ។ នៅក្នុងដំណើរទស្សនៈកិច្ចរបស់ លោកមកកាន់ប្រទេសកម្ពុជាកាលពីខែវិច្ឆិកា និងក្នុងរបាយការណ៍ នាពេលខាងមុខរបស់លោកជូនគណៈកម្មការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ លោកតំណាង ពិសេសបានកត់សំគាលថា ជាទូទៅលោកមានចំណាប់រម្មណ៍ជាវិជ្ជមានអំពីការរៀបចំនានាសំរាប់ការ បោះឆ្នោតឃុំនេះ។ ឥឡូវនេះ ការចំណាប់អារម្មណ៍នេះ កំពុងតែស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់នៃការ ធ្វើអោយស្រអាប់ពណ៌ដ៏ធ្ងន់ធ្ងរ ។

#16A, Mao Tse Tuong Blvd, Sangkat Tonle Bassac, Khan Chamcar Mon, Phnom Penh, Cambodia.
Tel: (855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342 Fax: (855) 23 212 579 or 213 587 E-mail: cohchr@online.com.kh
ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា លេខ ១៦A មហាវិថី ម៉ៅ សេទុង សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: ៨៥៥-២៣ ៩៨៧ ៦៧១ / ៩៨៧ ៦៧២ / ៩៩៣ ៥៩០ / ៩៩៣ ៥៩១ / ឬ ២១៦ ៣៤២ ទូរសារ: ៨៥៥-២៣ ២១២ ៥៧៩ ឬ ២១៣ ៥៨៧

# ១. សេចក្តីសង្ខេប

អំពើហិង្សា និងការបំភិតបំភ័យទាក់ទងនឹងការបោះឆ្នោតឃុំ-សង្កាត់នៅកម្ពុជា នៅឆ្នាំ២០០២នេះ កំពុងតែមានការប៉ះពាល់ដល់តំបន់ជាច្រើនក្នុងប្រទេស ។ ចាប់តាំងពីខែមករា ឆ្នាំ២០០១មក មាន សកម្មជននយោបាយចំនួន ១៥ នាក់ ត្រូវបានគេធ្វើឃាត ឬបានស្លាប់នៅក្នុងកាលៈទេសៈនានាដែលគួរ អោយមានការសង្ស័យ ។ ការស្លាប់ចំនួន ០៩ ក្នុងចំណោមការស្លាប់ទាំងនេះ បានកើតឡើងចាប់តាំងពី ដើមខែវិច្ឆិកាមក ហើយការស្លាប់ចំនួន ៣ ទៀត គឺបានកើតឡើងនៅក្នុងសប្តាហ៍ទី ១ នៃឆ្នាំ២០០២ ។ ដូច្នេះ អំពើហិង្សាដ៏ធ្ងន់ធ្ងរនេះហាក់ដូចជាកំពុងតែកើនឡើងនៅមុនការចាប់ផ្តើមយុទ្ធនាការឃោសនា បោះឆ្នោតជាផ្លូវការ ។

ការបំភិតបំភ័យចេះតែមានការរាលដាលដោយពុំមានការធូរស្រាលបន្តិចបន្តួចឡើយ ជាពិសេសនៅក្នុង ស្រុកនានានៅតាមបណ្តោយព្រំដែនភាគខាងលិចនៃផ្ទៃប្រទេស ក៏ដូចជានៅក្នុងតំបន់មួយចំនួននៅភាគ កណ្តាល និងភាគអាគ្នេយ៍របស់កម្ពុជាផងដែរ ។ របាយការណ៍នេះចង្អុលបង្ហាញអំពីតំបន់ជាក់លាក់មួយ ចំនួនដែលបញ្ហានានាកំពុងតែកើតមានឡើង ហើយត្រូវការអោយមានជាចាំបាច់នូវការចាត់វិធានការណ៍ ជាបន្ទាន់ ។ ការយកចិត្តទុកដាក់ជាពិសេស ត្រូវតែបានធ្វើឡើងចំពោះខេត្តចំនួន ២ គឺ ខេត្តកំពង់ចាម និងខេត្តកំពត និងចំពោះស្រុកចំនួន ២ នៅក្នុងខេត្តទាំងពីរនេះ គឺស្រុកត្បូងឃ្មុំ និងស្រុកឈូក ។ នេះគឺជាទស្សនៈរបស់តំណាងពិសេសរបស់ លោកអគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ដែលថា ជំហ៊ានជាបន្ទាន់នានាត្រូវតែបានធ្វើឡើងនៅក្នុងមូលដ្ឋានទាំងនេះ និងនៅក្នុងតំបន់ជុំវិញ ដើម្បី ដោះស្រាយការអនុវត្តន៏នានាដែលផ្ទុយយ៉ាងច្បាស់ក្រឡែតទៅនឹងច្បាប់ព្រហ្មទណ្ឌ និងច្បាប់បោះឆ្នោត របស់កម្ពុជា ដើម្បីដោះស្រាយបញ្ហានានាដែលមានជាយូរមកហើយដែលកើតចេញពីនីទណ្ឌភាព ។

គោលបំណងជាចំបងនៃរបាយការណ៍នេះ គឺត្រូវលើកយកបញ្ហាសំខាន់ៗទាំងឡាយដែលការិយាល័យ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជាបានដឹង ហើយនិងផ្តល់មកអោយ រាជរដ្ឋាភិបាលកម្ពុជា ជាមួយអនុសាសន៏នានាដើម្បីដោះស្រាយបញ្ហាបំភិតបំភ័យ ដើម្បីធ្វើអោយការ បោះឆ្នោតមួយប្រព្រឹត្តទៅដោយសេរី និងត្រឹមត្រូវ និងអនុលោមទៅតាមច្បាប់ជាតិ និង ច្បាប់អន្តរជាតិ នានាផងដែរ ។ រាជរដ្ឋាភិបាលត្រូវតែបង្ហាញជូនចំពោះអ្នកបោះឆ្នោតអោយឃើញប្រកបដោយ ប្រសិទ្ធិភាពថា បុគ្គលទាំងឡាយដែលទទួលខុសត្រូវចំពោះអំពើហិង្សា និងការបំភិតបំភ័យ ត្រូវបាន ចាត់ការប្រកបដោយប្រសិទ្ធិភាព និងដោយអនុលោមទៅតាមច្បាប់ ។ រហូតមកទល់នឹងពេលនេះ ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ដឹងថាមានតែករណីមួយប៉ុណ្ណោះដែល

ទាក់ទងនឹងការបោះឆ្នោត ដែលក្នុងនោះបុគ្គលពាក់ពន្ធ័ត្រូវបានគេនាំខ្លួនមកកាត់ទោស និងផ្តន្ទាទោស ក្នុងឆ្នាំ២០០១។ បទបញ្ញត្តិនៃច្បាប់ព្រហ្មទណ្ឌ និងបទបញ្ញត្តិនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាឃុំ-សង្កាត់ គឺមិនត្រូវបានអនុវត្តអោយបានពេញលេញនៅឡើយទេ។ អំណាចដើម្បីធ្វើការ ស៊ើបអង្កេត និងដាក់ទណ្ឌកម្ម ចំពោះបទរំលោភលើច្បាប់បោះឆ្នោត គឺស្ថិតនៅលើគណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោត។ ទោះបីជាករណីជាច្រើនត្រូវបានជំរាបជូនគណៈកម្មាធិការជាតិរៀបចំការ បោះឆ្នោតហើយក៏ដោយ ក៏គណៈកម្មាធិការមិនទាន់មានចេតនាអោយបានមុតមាំ ដើម្បីអនុវត្តបទបញ្ញត្តិ ពាក់ពន្ធ័របស់ច្បាប់ នៅឡើយទេ ។

បញ្ហានៃការប្រមូលប័ណ្ណបោះឆ្នោតដោយខុសច្បាប់ដោយអាជ្ញាធរឃុំ និងភូមិ ត្រូវបានរាយការណ៍មកថា មាននៅក្នុងផ្នែកជាច្រើននៃប្រទេស។ អ្វីដែលសំខាន់ដើម្បីធ្វើការកត់សំគាល់នៅទីនេះ គឺថាបទល្មើស តូចតាច ដែលរួមមានទាំងការអនុវត្តន៏នានាដូចជាការបំផ្លាញផ្លាកគណបក្សនយោបាយជាដើម ទំនងជា មានការផលប៉ះពាល់ដែលមានចរិតជាការបំភិតបំភ័យដ៏មានឥទ្ធិពលមួយ នៅក្នុងបរិយាកាសនយោបាយ ដ៏ផុយស្រួយរបស់កម្ពុជា និងដោយយោងទៅលើបទពិសោធន៏នាពេលកន្លងមករបស់ខ្លួន។ នេះគឺជា ការពិត ជាពិសេសនៅក្នុងទីកន្លែងនានា ដែលអ្នកបោះឆ្នោតបានឃើញអំពើហិង្សានៅក្នុងរយៈពេលមុន ការបោះឆ្នោតនេះ និងនៅក្នុងអំឡុងការបោះឆ្នោតជាសាកលក្នុងឆ្នាំ១៩៩៣ និង១៩៩៨។ វាគឺជាការ មានសារៈសំខាន់ដែលថា អ្នកដែលបានប្រព្រឹត្តត្រូវតែទទួលខុសត្រូវ ហើយដែលថាកិច្ចខិតខំផ្នែកអប់រំ អ្នកបោះឆ្នោតពិសេស ត្រូវធ្វើឡើងនៅក្នុងតំបន់នានាដែលប៉ះពាល់ ដើម្បីធានា និងធ្វើអោយ អ្នកបោះឆ្នោតអោយបានយល់ដឹង។

ក្នុងករណីបំភិតបំភ័យភាគច្រើន មន្ត្រីអាជ្ញាធរមូលដ្ឋាននៅថ្នាក់ឃុំ និងភូមិ និងនគរបាលឃុំ គឺជាអ្នក ទទួលខុសត្រូវ។ ជនរងគ្រោះនៅក្នុងករណីប្រហែលជា ២/៣ នៃករណីទាំងអស់ គឺជាបេក្ខជន និងជា សកម្មជនគណបក្សសមរង្ស៊ី។ នៅក្នុងករណីដែលនៅសេសសល់ភាគច្រើនជាបេក្ខជន និងសកម្មជន ដែលតំណាងអោយគណបក្សហ៊្វុនស៊ីនប៉ិច គឺជាមុខសញ្ញា។

លោកតំណាងពិសេសសូមអំពាវនាវដល់រាជរដ្ឋាភិបាល និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អោយចាត់វិធានការណ៏ជាបន្ទាន់ ដោយធ្វើតាមអនុសាសន៏ដែលមាននៅក្នុងរបាយការណ៏នេះ។ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ គឺជាការបោះជំហ៊ានមួយថែមទៀតឆ្ពោះទៅរក ការពង្រឹងប្រពន្ធ័ប្រជាធិបតេយ្យសេរីពហុបក្ស ដែលជាការទទួលខុសត្រូវចំពោះបំណងប្រាថ្នារបស់



នេះជាការបកប្រែពីអត្ថបទដើមដែលជាភាសាអង់គ្លេស

ប្រជាពលរដ្ឋកម្ពុជា។ ពួកគេបានតាមដានការបោះឆ្នោតនៅក្នុងឆ្នាំ១៩៩៣ និងក្នុងឆ្នាំ១៩៩៨ ដែលបានធ្វើអោយមានសៅហ្មងដោយមានឃាតកម្ម ហិង្សា និងការបំភិតបំភ័យ។ ការរំលោភទាំងឡាយបែបនោះមិនត្រូវអនុញ្ញាតអោយចាក់រឹសបែបជាបទដ្ឋានបោះឆ្នោតមួយនោះឡើយ ។

## ២_ បណ្តាស្រុកដែលមានបញ្ហាកើតឡើង

ការរាលដាលនៃឧប្បត្តិហេតុដែលទាក់ទងនឹងការបោះឆ្នោត ដោយគិតទៅតាមតំបន់ភូមិសាស្ត្របង្ហាញអោយឃើញអំពីតំបន់ ២ ខុសគ្នា ដែលមានបញ្ហាដ៏ធ្ងន់ធ្ងរកំពុងកើតឡើង។ តំបន់ទី ១ រួមមានខេត្តទាំងឡាយនៅភាគកណ្តាល និងភាគអគ្នេយ៍ ពោលគឺ កំពង់ចាម ព្រៃវែង កណ្តាល និងកំពត។ តំបន់ផ្សេងទៀត រួមមានខេត្តទាំងឡាយដែលនៅតាមព្រំដែនភាគខាងលិចនោះគឺ បាត់ដំបង បន្ទាយ-មានជ័យ និងក្រុងប៉ៃលិន។ នៅក្នុងឧប្បត្តិហេតុចំនួន ២/៣ នៃឧប្បត្តិហេតុទាំងអស់ ដែលការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជាបានដឹងថា ជនរងគ្រោះគឺជាបេក្ខជន ឬជាសកម្មជនរបស់គណបក្ស សម រង្ស៊ី។ ស្ទើរទាំងអស់នៃ ករណីដែលនៅសេសសល់ គឺពាក់ពន្ធ័នឹងបុគ្គលទាំងឡាយដែលមានការទាក់ទងជាមួយគណបក្សហ្វ៊ុនស៊ិនប៊ិច។

**តំបន់ភាគខាងលិចរបស់កម្ពុជា**

ខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ រួមជាមួយក្រុងប៉ៃលិន គឺជាខេត្ត ដែលបានកត់ត្រាទុកនូវចំនួននៃបញ្ហាដែលបានកើតមានឡើងទាក់ទងនឹងការបោះឆ្នោត ច្រើនជាងតំបន់ផ្សេងទៀតរបស់កម្ពុជា ចាប់ពីតាំងថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០១មក។ ការស៊ើបអង្កេតដោយការិយាល័យឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជាបានកំណត់ថា ការទទួលខុសត្រូវចំពោះចំនួនដ៏ច្រើននៃការរំលោភច្បាប់នៅក្នុងតំបន់ទាំងនេះ គឺទាក់ទិនជាមួយសមាជិកនៃកងយុទ្ធពលខេមរៈភូមិន្ទ។ ការព្រួយបារម្ភជាពិសេសនោះ គឺឥរិយាបទរបស់យោធានៅក្នុងស្រុកសំពៅលូន ភ្នំព្រឹក កំរៀង កោះក្រឡ និងសំឡូត ។

ករណីទាំងឡាយ ដែលបានរាយការណ៏មកការិយាល័យឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា រួមមានករណីឃាតកម្ម និងករណីនៃការប៉ុនប៉ងធ្វើឃាតកម្ម ឧប្បត្តិហេតុនៃការឃុំខ្លួនដោយខុសច្បាប់ដែលបានកើតឡើងម្តងហើយម្តងទៀត និងការបំភិតបំភ័យដ៏ធ្ងន់ធ្ងរជាច្រើនទៀ។ ក្នុងចំណោមករណីទាំងនោះ មានឧប្បត្តិហេតុមួយកើតឡើងក្នុងស្រុកកំរៀងក្នុងខេត្តបាត់ដំបង កាលពី



នេះជាការបកប្រែពីអត្ថបទដើមដែលជាភាសាអង់គ្លេស

ថ្ងៃទី១៥ ខែកញ្ញា ដែលនៅទីនោះ មានទាហានចំនួន ២ នាក់ត្រូវបានឃុំខ្លួន និងចោទប្រកាន់ពីបទជាប់ពាក់ពន្ធ័ជាមួយចលនាកងទ័ពសេរីជាតិកម្ពុជា បន្ទាប់ពីបានសុំច្បាប់ឈប់សំរាកដើម្បីឈរឈ្មោះជាបេក្ខជនរបស់គណបក្ស សម រង្ស៊ី ។ នៅក្នុងស្រុកសំឡូតនៃខេត្តបាត់ដំបង កាលពីថ្ងៃទី ០៨ ខែតុលា មានបេក្ខជនគណបក្សសមរង្ស៊ីចំនួន ៤ នាក់ ត្រូវបានគេហៅអោយមកការិយាល័យគណបក្សប្រជាជននៅមូលដ្ឋាននោះ ដែលពួកគេត្រូវបានទទួលការគំរាមកំហែង ។ នៅថ្ងៃទី០២ ខែតុលា នៅស្រុកអូរជ្រៅនៃខេត្តបន្ទាយមានជ័យ ជនប្រដាប់អាវុធបានហ៊ុំព័ទ្ធផ្ទះរបស់សមាជិកគណបក្សហ៊ុនស៊ីនប៊ិច ដោយបណ្តើរគាត់ចេញដោយភ្ជង់នឹងចុងកាំភ្លើង ហើយបានឃុំខ្លួនគាត់អស់រយៈពេលជាច្រើនម៉ោង ។ គាត់ត្រូវបានគេប្រាប់ថាប្រសិនបើគាត់មិនចូលរួមជាមួយគណបក្សប្រជាជនទេ នោះគាត់នឹងត្រូវបានគេចាត់ទុកថាជាសមាជិកនៃកងទ័ពសេរីជាតិកម្ពុជា ។

កត្តាជាទូទៅមួយក្នុងចំណោមស្រុកទាំងឡាយនៅក្នុងខេត្តបន្ទាយមានជ័យ និងក្រុងប៉ៃលិន ដែលមានបញ្ហាកើតឡើង គឺថានៅក្នុងការបោះឆ្នោតឆ្នាំ១៩៩៨ មានការគាំទ្រខ្ពស់ពីអ្នកបោះឆ្នោតចំពោះគណបក្ស សម រង្ស៊ី ។ នៅទីនេះ ស្រុកនានាដែលត្រូវបានរាយការណ៍មកថាមានបញ្ហាច្រើនបំផុតកើតឡើងនោះ គឺស្រុកម៉ាឡៃនៅក្នុងខេត្តបន្ទាយមានជ័យ និងខ័ណ្ឌប៉ៃលិន និងសាលាក្រៅនៅក្នុងក្រុងប៉ៃលិន ។ នៅក្នុងស្រុក/ខណ្ឌ័នៃតំបន់ទាំងនេះ គណបក្ស សម រង្ស៊ី មានចំណែកសន្លឹកឆ្នោតក្នុងឆ្នាំ១៩៩៨ ច្រើនជាង ៤០% [១] ។

នៅខេត្តបាត់ដំបង ភាពទាក់ទងគ្នាដ៏ច្បាស់រវាងការបោះឆ្នោតជាសាកលឆ្នាំ១៩៩៨ ការបំភិតបំភ័យ និងអំពើហិង្សាក្នុងអំឡុងពេលមុនការបោះឆ្នោតឃុំក្នុងឆ្នាំ២០០១ បង្ហាញអោយឃើញអំពីការពុំមានបញ្ហាទាល់តែសោះ ដែលត្រូវបានរាយការណ៍នៅក្នុងស្រុកចំនួន ២ ដែលសន្លឹកឆ្នោតរបស់គណបក្សប្រជាជនមានចំនួនច្រើនជាង៤០% ( គឺស្រុកបវិល និងបាណន់) [២] ។ ប៉ុន្តែនៅទីណាដែលសន្លឹកឆ្នោតរបស់គណបក្សប្រជាជនមានចំនួនតិចជាងក៏រិតនេះ ស្ថានភាពផ្ទុយពីនេះគឺជាការពិត ។ បញ្ហាទាំងឡាយត្រូវបានរាយការណ៍ថាកើតមានក្នុងស្រុកសំឡូត ភ្នំព្រឹក សំពៅលូន កំរៀង កោះក្រឡ បាត់ដំបង រតនៈមណ្ឌល និងឯកភ្នំ ច្រើនជាងតំបន់ណាផ្សេងៗទៀតរបស់កម្ពុជា ។

---

[១] ទិន្នន័យរបស់គណៈកម្មការអឺរ៉ុប

[២] ជាទូទៅ តំបន់ទាំងឡាយរបស់កម្ពុជា ដែលមានការគាំទ្រខ្លាំងពីអ្នកបោះឆ្នោតលើគណបក្សប្រជាជន មានឧប្បត្តិហេតុតិចតួចដែលបានកត់ត្រាទុក ។

កត្តាមួយទៀត ហើយដែលមាសក្តានុពលបំផុត ដែលនៅពីក្រោយព្រឹត្តិការណ៍ទាំងនេះអាចជាភាព សម្បូណ៌នៃធនធានធម្មជាតិនៅក្នុងតំបន់នេះ គួបផ្សំជាមួយនឹងលទ្ធភាពច្រើនសំរាប់អ្នកទាំងឡាយណា ដែលមានអំណាចដើម្បីត្រួតត្រា ឬទទួលបានផលប្រយោជន៍ពីជំនួញឆ្លងកាត់ព្រំដែន។ វាគួរអោយ កត់សំគាល់ដែរថាឧប្បត្តិហេតុទាំងឡាយ ត្រូវបានគេកត់ត្រាទុកក្នុងគ្រប់ស្រុកដែលស្ថិតនៅជាប់ព្រំដែន ពីអូរជ្រៅ នៅភាគជាជើង ទៅសំឡូត នៅភាគខាងត្បូង។

រហូតដល់ឆ្នាំ១៩៩៦ តំបន់ជាច្រើននៅក្បែរព្រំដែន គឺស្ថិតនៅក្រោមការត្រួតត្រារបស់ខ្មែរក្រហម ហើយកងកំលាំងប្រដាប់អាវុធនៅក្នុងតំបន់ទាំងនេះ ភាគច្រើនគឺជាអតីតទាហានខ្មែរក្រហម។ ប៉ុន្តែ ទោះជាស្ថានភាពនយោបាយមានស្ថេរភាពជាងតាំងពីពេលនោះមកក៏ដោយ វាហាក់ដូចជាមានភាព ធ្ងន់ធ្ងរគួរកត់សំគាល់ជាងបរិយាកាសមុនការបោះឆ្នោតនៅឆ្នាំ១៩៩៨ នៅក្នុងតំបន់នេះ។ ជំហ៊ាន ទាំងឡាយដើម្បីការពារបេក្ខជននៅក្នុងតំបន់ទាំងនេះពីការបំភិតបំភ័យតទៅទៀតនោះ គឺត្រូវអោយ ចាត់វិធានការណ៍ជាបន្ទាន់ទាំងឡាយឡើង ដើម្បីធ្វើអោយអ្នកបោះឆ្នោតមានទំនុកចិត្ត។ វាក៏មានសេចក្តី ត្រូវការជាបន្ទាន់ផងដែរ ដើម្បីអោយមានវិធានការណ៍ដោះស្រាយបញ្ហានីទណ្ឌភាព រាប់បញ្ចូល ទាំងតាមរយៈការចាប់ផ្តើមត្រួតពិនិត្យអោយបានតឹងរ៉ឹងលើសមាជិកនៃកងកំលាំងប្រដាប់អាវុធពាក់ពន្ធ័ និងធានាថាអ្នកទាំងឡាយដែលទទួលខុសត្រូវ ត្រូវបានចាត់ការដោយអនុលោមទៅតាមច្បាប់។

## ខេត្តនៅភាគកណ្តាល និងអាគ្នេយ៍

នៅខេត្តកំពង់ចាម កំពត កណ្តាល និងព្រៃវែង គេឃើញការរំលោភដែលទាក់ទងនឹងការបោះឆ្នោត ដ៏ធ្ងន់មួយចំនួនដែលត្រូវបានកត់ត្រាទុករហូតមកទល់នឹងពេលនេះ។ ទោះបីជាថាមានរបាយការណ៍អំពី ឧប្បត្តិហេតុតិចតួចជាងក្នុងតំបន់ភាគខាងលិចនៃកម្ពុជាក៏ដោយ ឧប្បត្តិហេតុទាំងនេះហាក់ដូចជាមានភាព ធ្ងន់ធ្ងរច្រើនជាង។ វាគឺជាទស្សនៈរបស់លោកតំណាងពិសេសដែលថា ស្រុកត្បូងឃ្មុំក្នុងខេត្តកំពង់ចាម និងស្រុកឈូកក្នុងខេត្តកំពត គួរទទួលបាននូវការយកចិត្តទុកដាក់ជាពិសេស។

ស្រុកត្បូងឃ្មុំ និងស្រុកទាំងឡាយដែលនៅជិតខាង នៅសងខាងទន្លេមេគង្គ បានកត់ត្រាទុកនូវបញ្ហា គួរអោយកត់សំគាល់ដែលបានកើតឡើងនៅក្នុងអំឡុងមុនការបោះឆ្នោតឆ្នាំ១៩៩៨ ហើយគំរូបែបនោះ នៅបន្តមានមកទៀត។ ការស្លាប់ចំនួន ៣ ក្នុងចំណោមការស្លាប់ទាក់ទងនឹងការបោះឆ្នោតទាំងឡាយ នៅកម្ពុជាបានកើតឡើងក្នុងស្រុកត្បូងឃ្មុំ ចាប់តាំងពីដើមឆ្នាំ២០០១មក។ ការគំរាមកំហែងចំៗ និងការគំរាមកំហែងថាសំលាប់ចោល ត្រូវបានធ្វើឡើងប្រឆាំងនឹងបេក្ខជនឈរឈ្មោះបោះឆ្នោត ឯនៅក្នុង

ស្រុកពញាក្រែកដែលជាស្រុកនៅជិតខាងនោះ គឺទ្រព្យសម្បត្តិរបស់កសិករដែលមានទំនាក់ទំនងជាមួយគណបក្ស សម រង្ស៊ី ជាមុខសញ្ញានៃការវាយប្រហារដោយការដុតបំផ្លាញជាបន្តបន្ទាប់ កាលពីចុងខែធ្នូ ឆ្នាំ២០០១។ ជនរងគ្រោះ និងសាក្សីនៅក្នុងតំបន់នេះ ជារឿយៗមានការភ័យខ្លាច មិនហ៊ាននិយាយស្តី។ វាហាក់ដូចជាលេចឡើងថា សមាជិកនៃកងកំលាំងប្រដាប់អាវុធដែលពាក់ពន្ធ័ ត្រូវបានការពារដោយមេរបស់ពួកគេ។

នៅស្រុកឈូកក្នុងខេត្តកំពត មានការកត់ត្រាទុកនូវករណីចំនួនច្រើនប្រហាក់ប្រហែលគ្នា។ ឃាតកម្មចំនួន ២ ដែលកើតឡើងនៅក្បែរស្រុកជុំគីរីនៅក្នុងសប្តាហ៍ទី១ នៃឆ្នាំ២០០២ ជាប់ពាក់ពន្ធ័ជាមួយបេក្ខជនឈរឈ្មោះបោះឆ្នោតម្នាក់ក្នុងស្រុកឈូក។ អំពើហិង្សា និងការបំភិតបំភ័យ ហាក់ដូចជាមានភាពធ្ងន់ធ្ងរជាពិសេសនៅក្នុងឃុំតាកែន និងត្រពាំងភ្លាំង។ វាមានសារៈសំខាន់គួរកត់សំគាល់ផងដែលថា ទីនេះក៏ដូចជានៅទីកន្លែងផ្សេងទៀតដែរ ឥទ្ធិពលនៃអំពើហិង្សា និងការបំភិតបំភ័យលើសហគមន៍មួយគឺជារឿយៗ ត្រូវបានគេធ្វើនីហរណកម្មទៅកាន់សហគមន៍ផ្សេងទៀត តាមរយៈការឆ្លងឥទ្ធិពលនៃការភ័យខ្លាច។

ឃាតកម្មទាំងឡាយដែលបានកើតឡើងលើសកម្មជននយោបាយ មានរៀបរាប់ពិស្តារនៅផ្នែកផ្សេងទៀតក្នុងរបាយការណ៍នេះ។ ការបំភិតបំភ័យ និងរូបភាពនៃការបោកប្រាស់ផ្សេងទៀតនៅក្នុងខេត្តទាំងនេះមានការរាលដាល និងមានផាពធ្ងន់ធ្ងរ។ នៅថ្ងៃទី១០ ខែកក្កដា នៅស្រុកតំបែរនៃខេត្តកំពង់ចាម មេបញ្ជាការយោធា និងអាជ្ញាធរភូមិបានប្រាប់សកម្មជនគណបក្ស សម រង្ស៊ី ថាប្រសិនបើគាត់មិនដកផ្លាកគណបក្សចេញទេនោះ ផ្ទះរបស់គាត់នឹងត្រូវគេដុតបំផ្លាញចោល។ នៅថ្ងៃទី០១ ខែតុលា របាយការណ៍មួយដែលការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជាបានទទួល និយាយថាអ្នកភូមិនៅក្នុងស្រុកកោះធំនៃខេត្តកណ្តាល ត្រូវបានគេរៀបចំដាក់ជាក្រុម ដើម្បីធានាថាសមាជិកមួយរូប១បោះឆ្នោតអោយគណបក្សប្រជាជន។ នៅស្រុកឈូកនៃខេត្តកំពត នៅខែសីហា អាជ្ញាធរមូលដ្ឋានបដិសេធនឹមិន ទទួលស្គាល់ការស្នាក់នៅរបស់បេក្ខជនដែលត្រៀមឈរឈ្មោះរបស់គណបក្សហ៊ុនស៊ីនប៉ិចចំនួន ៣ នាក់  ទោះបីជាពួកគេបានរស់នៅទីនោះចំនួន៤ឆ្នាំហើយក៏ដោយ។ ដូច្នេះពួកគេត្រូវបានបដិសេធន៍សិទ្ធិឈរឈ្មោះអោយគេបោះឆ្នោត ឬសិទ្ធិចុះឈ្មោះជាអ្នកបោះឆ្នោត។ នៅស្រុកមេមុតនៃខេត្តកំពង់ចាម នៅថ្ងៃទី២៣ ខែសីហា សមាជិកគណបក្ស សម រង្ស៊ី ត្រូវបានគេសួរនាំអំពីគោល

បំណងនៃការបោះឆ្នោតរបស់គាត់ ហើយបន្ទាប់មកត្រូវបានគេប្រាប់ថា គ្រាប់កាំភ្លើងនឹងទំលុះថ្វាស របស់គាត់ ប្រសិនបើគាត់មិន"ធ្វើតាម"ទេនោះ។

ក៏ដូចជានៅក្នុងតំបន់ភាគច្រើនផ្សេងទៀតនៃប្រទេសដែរ វាហាក់ដូចជាថា មន្ត្រីអាជ្ញាធរមូលដ្ឋាន ជាពិសេសនៅថ្នាក់ភូមិ និងឃុំ និងនគរបាលឃុំ គឺជាអ្នកទទួលខុសត្រូវចំពោះអំពើហិង្សា និងការបំភិត បំភ័យជាច្រើន។ ប៉ុន្តែ នៅក្នុងខេត្តភាគកណ្តាល និងផាគអាគ្នេយ៍របស់កម្ពុជា ភាពទាក់ទងគ្នារវាងបញ្ហា និងតុល្យភាពនៃអំណាច ពីការបោះឆ្នោតឆ្នាំ១៩៩៨ មានលក្ខណៈមិនសូវច្បាស់លាស់ដូចនៅក្នុង តំបន់ជាប់ព្រំដែនខាងលិចនោះទេ។ ជាទូទៅ វាមានចំនួននៃឧប្បត្តិហេតុស្មើគ្នាទាំងនៅក្នុងស្រុក ដែលត្រួតត្រាដោយគណបក្សប្រជាជន និងទាំងនៅក្នុងស្រុកដែលត្រួតត្រាដោយគណបក្សហ៊្វុនស៊ិុប៊ិច។

## ៣_ការសំលាប់ និងការស្លាប់ដែលមិនទាន់បានដោះស្រាយ

ចាប់តាំងពីថ្ងៃទី០១ ខែមករា ឆ្នាំ២០០១មក មានសកម្មជនគណបក្សនយោបាយចំនួនដប់ប្រាំ (១៥)[៣] នាក់ បេក្ខជនដែលត្រៀមឈរឈ្មោះ បេក្ខជនពិតប្រាកដ ព្រមទាំងបុគ្គលដែលសកម្មក្នុងរឿងនយោបាយ ដ៏ទៃទៀត ត្រូវបានគេធ្វើឃាត ឬស្លាប់ នៅក្នុងកាលៈទេសៈដែលគួរអោយសង្ស័យ។ ការស្លាប់ចំនួន ប្រាំបួន(៩) នៃចំនួនទាំងនេះបានកើតមានចាប់តាំងពីខែដើមខែវិច្ឆិកា ហើយការស្លាប់ចំនួនបី(៣) កើតមានឡើងនៅក្នុងសប្តាហ៍ទីមួយនៃឆ្នាំ២០០២។ ប្រការនេះហើយ ដែលការកើតឡើងជាញយៗនេះ ហាក់ដូចជាមានការកើនឡើងនៅមុនដំណាក់កាលធ្វើយុទ្ធនាការឃោសនាបោះឆ្នោត។

[៣] -តួលេខចំនួន១៥នាក់នេះ គឺមិនរាប់បញ្ចូលសកម្មជនគណបក្សហ៊្វុនស៊ីនប៊ិចពីររូបដែលគេសំលាប់កាលពីថ្ងៃទី០៥ ខែកមរា ឆ្នាំ២០០២ នៅក្នុង ខេត្តកំពង់ចាម ដែលហាក់បីដូចជាបណ្តាលមកពីគ្រោះថ្នាក់ចរាចរ។ ការិយាល័យឧត្តមស្នងការអង្គការ សហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជាកំពុងតែបន្តការស៊ើបអង្កេតទៅលើករណីនេះ។ **ការស្លាប់ដ៏ទៃទៀត:** កាលពីថ្ងៃទី០៧ ខែមករា ឆ្នាំ២០០២ សកម្មជនគណបក្សហ៊្វុនស៊ិនប៊ិចមួយរូប ស្លាប់ដោយគ្រោះថ្នាក់ចរាចរ នៅក្នុងស្រុកកំពង់សៀម ខេត្តកំពង់ចាម ដែលការស្លាប់នេះគឺជាគ្រោះថ្នាក់ចរាចរទាំងស្រុង។ នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០១ មេភូមិគណបក្សប្រជាជាជនមួយរូប និងមិត្តភ័ក្រ្តមួយរូបទៀត ត្រូវបានគេសំលាប់នៅក្នុង ស្រុកពញាក្រែក ខេត្តកំពង់ចាម ដែលបុគ្គលទាំងនេះមិនជាសកម្មនៅក្នុងដំណើរការបោះឆ្នោតនោះទេ។ នៅថ្ងៃទី០២ ខែមករា ឆ្នាំ២០០២ ភរិយារបស់មេភូមិ ដែលត្រៀមឈ្មោះរបស់គណបក្សហ៊្វុនស៊ិនប៊ិចមួយរូប ត្រូវបានគេបាញ់សំលាប់នៅក្នុងខេត្តកំពត-ពួកគាត់មិនជាសកម្មនៅក្នុង ដំណើរការបោះឆ្នោតនោះទេ។

ការព្រួយបារម្ភបំផុត គឺការស្លាប់ទីបីក្នុងចំណោមការស្លាប់ទាំងនេះ កើតមានតែនៅក្នុងខេត្តកំពង់ចាម មួយគត់ ។ ការសំលាប់ទាំងនេះបានកើតមាននៅក្នុងតំបន់ ដែលបញ្ហាទីទណ្ឌភាពត្រូវបានកត់ត្រា ផងដែរនៅក្នុងអំឡុងពេលបោះឆ្នោតឆ្នាំ១៩៩៨[៤] ។ ការសំលាប់បីក្នុងចំណោមការសំលាប់នៅក្នុងខេត្ត កំពង់ចាម កើតមាននៅក្នុងស្រុក ត្បូងឃ្មុំ (សូមមើលផ្នែកស្តីពីស្រុកដែលមានបញ្ហា) ហើយករណី ចំនួនពីរក្នុងចំណោមករណីទាំងនេះអាចមានការទាក់ទិនគ្នា[៥] ។

ក្នុងខណៈដែលមានករណីបំភិតបំភ័យស្ទើរតែទាំងអស់ទាក់ទិនទៅនឹងសកម្មជនគណបក្ស សម រង្ស៊ី ការស្លាប់បានរាលដាលតិច ឬច្រើនរវាងគណបក្សហ៊្វុនស៊ីនប៉ិច និងគណបក្ស សម រង្ស៊ី ។ ការស្លាប់ចំនួនប្រាំ (៥) ក្នុងចំណោមប្រាំពីរ(៧)របស់គណបក្សហ៊្វុនស៊ីនប៉ិចបានកើតមានចាប់តាំងពីដើមខែវិច្ឆិកាមកម្ល៉េះ ។ ការស្លាប់ចំនួនបួន(៤) ក្នុងចំណោមប្រាំបី(៨)របស់គណបក្ស សម រង្ស៊ី ក៏បានកើតមានឡើងនៅក្នុង អំឡុងសប្តាហ៍ចុងក្រោយនៃឆ្នាំ២០០១ ។ ពុំឃើញមានការសំលាប់សកម្មជនរបស់គណបក្សនយោបាយ ផ្សេងទៀតដែលទាក់ទិនទៅនឹងការបោះឆ្នោតនោះទេ ។

ឃាតកម្មចំនួនដប់ពីរ(១២)កើតឡើងដោយការបាញ់សំលាប់ ។ ក្រៅពីនេះ យ៉ាងហោចណាស់មានករណី ចំនួនពីរ ដែលជនរងគ្រោះត្រូវបានគេវាយដំរហូតដល់ស្លាប់ ។ មានករណីតែមួយគត់ដែលពុំមានមូលហេតុ ច្បាស់លាស់: សាកសព របស់បេក្ខជនគណបក្សហ៊្វុនស៊ីនប៉ិច ឈ្មោះ រស់ ជន ត្រូវបានគេរកឃើញ នៅថ្ងៃទី១៤ ខែកុម្ភៈ នៅក្នុងស្នាមភ្លោះ ក្បែរផ្លូវថ្នល់នៅក្នុងស្រុកពួក ខេត្តសៀមរាម ។ នគរបាលនិយាយ ថាវាជាគ្រោះថ្នាក់ចរាចរដោយអកុសល ប៉ុន្តែការស៊ើបអង្កេតជាបន្តទៅទៀតគឺជាការចាំបាច់ ដើម្បីបំបាត់ ចោលនូវលទ្ធកម្មទាំងនេះ ។

---

[៤] -ខេត្តកំពង់ចាមបានកើតមានបទល្មើសជាច្រើននៅមុនអំឡុងពេលបោះឆ្នោតឆ្នាំ១៩៩៨ ។ បទល្មើសទាំងនេះរួមទាំងការ សំលាប់សមាជិក គណបក្ស សម រង្ស៊ី មួយរូប ឈ្មោះ អែម អៀម ដែលត្រូវបានចាប់ខ្លួនដោយមន្ត្រីនៅក្នុងស្រុកត្បូងឃ្មុំ ហើយក្រោយមកក៏យកទៅប្រហារជីវិតចោល ។ បុគ្គលពីររូប ម្នាក់នៅក្នុងស្រុកត្បូងឃ្មុំ និងម្នាក់ទៀតនៅក្នុងស្រុកអូររាំងឪ ត្រូវបានគេឃុំខ្លួនដោយខុសច្បាប់នៅក្នុងពន្ធនាគារ ។ មានករណីគំរាមកំហែងដល់អាយុជីវិតចំនួនពីរ និងករណីបំភិតបំភ័យ មួយចំនួនទៀត ។

[៥] -ទូច ផល្លី និង ភួង សុផាត ម្នាក់ជាសកម្មជនគណបក្សហ៊្វុនស៊ីនប៉ិច និងម្នាក់ជាសកម្មជនគណបក្ស សម រង្ស៊ី ត្រូវបានគេ បាញ់សំលាប់នៅក្នុងឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ។ ការសំលាប់ទាំងនេះមានគម្លាតពេលពីគ្នាតិចជាងពីរម៉ោង ។ ចំនួនជនដៃដល់ នៅក្នុងព្រឹត្តិការណ៍នីមួយៗមានចំនួន ប្រហាក់ប្រហែលគ្នា ។ អាវុធប្រភេទតែមួយហាក់ដូចជាបានយកមកប្រើសំរាប់ការសំលាប់ ទាំងពីរករណីនេះ ។ ចាប់តាំងពីមានការសំលាប់នោះមក មានការបំភិតបំភ័យធ្ងន់ធ្ងរបន្ថែមទៀតដល់គណបក្សហ៊្វុនស៊ីនប៉ិច នៅក្នុងឃុំនេះ ។



នេះជាការបកប្រែពីអត្ថបទដើមដែលជាភាសាអង់គ្លេស

ការស៊ើបអង្កេតរបស់នគរបាលទៅលើឧប្បត្តិហេតុទាំងនេះ ហើយនិងកិច្ចដំណើរការតាមផ្លូវតុលាការជាបន្តបន្ទាប់ បានបង្ហាញអោយឃើញថាមានគុណវិបត្តិជាខ្លាំង។ អាជ្ញាធរស៊ើបអង្កេតនៅមានការស្ទាក់ស្ទើរក្នុងការស្វែងរកមូលហេតុខាងនយោបាយ ធ្វើអោយការគ្រោះថ្នាក់កាន់តែកើតមានច្រើនឡើងនៃការធ្វើសេចក្តីសន្និដ្ឋានជាមុន ដែលជាការពន្យាពេលវេលា។ ឧទាហរណ៍មួយនៃការស្លាប់របស់ ទូច វឿន ដែលជាបេក្ខជនបំរុងនឹងឈរឈ្មោះ របស់គណបក្ស សម រង្ស៊ី នៅខេត្តសៀមរាប។ វឿន ត្រូវបានគេបាញ់សំលាប់កាលពីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០១ ក្នុងពេលកំពុងដេកនៅផ្ទះ។ នៅពេលដំបូងនៃការស៊ើបអង្កេត នគរបាលបាននិយាយជាសាធារណៈថា ករណីនេះ មិនមានពាក់ព័ន្ធរឿងនយោបាយទេ។ ពួកគេបានចាប់ខ្លួនសាច់ញាតិម្នាក់របស់ជនរងគ្រោះដោយច្រលំ ហើយក្រោយមកបានឃុំខ្លួនគាត់អស់រយៈពេលពីរខែ។ ជនជាប់សង្ស័យក្រោយៗទៀតត្រូវបានឃុំខ្លួនលើសរយៈពេល៤៨ម៉ោង ដែលច្បាប់អនុញ្ញាត។ ក្នុងអំឡុងពេលនៃការ ធ្វើសម្ភាសន៏ដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា កាលពីថ្ងៃទី ២០ ខែវិច្ឆិកា ជនជាប់សង្ស័យពីរនាក់ក្នុងចំណោមទាំងនេះមានស្លាកស្នាមនៅលើរាងកាយ ដែលហាក់ដូចជាដោយការធ្វើទារុណកម្ម។

ដីកាកោះហៅ និងដីកាឆែកឆេរត្រូវបានចេញចំពោះការសំលាប់ផ្សេងទៀត ប៉ុន្តែមិនបានអនុវត្តទេ ដែលហាក់បីដូចជា ដោយសារជនជាប់សង្ស័យត្រូវបានយោធាការពារអោយរួចផុតពីការចាប់ខ្លួន។ ឧទាហរណ៍មួយ គឺតុលាការខេត្ត កំពង់ចាមបានចេញដីកាកោះហៅ និងដីកាឆែកឆេរនៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០១ ចំពោះ ឈ្មោះ តាំង ឡាយ ដែល ជាជនជាប់សង្ស័យនៅក្នុងការសំលាប់សកម្មជនគណបក្ស សម រង្ស៊ី ម្នាក់ឈ្មោះ ភួង ផាន់ កាលពីថ្ងៃទី០៣ ខែមករា ឆ្នាំ២០០១។ ផ្ទះរបស់ តាំង ឡាយ ចិតនៅជិតមូលដ្ឋានកងទ័ព ង-៤៣ នៅក្នុងស្រុកតំបែរ ខេត្តកំពង់ចាម។ មកទល់ នឹងខែធ្នូ ដីកាទាំងនេះមិនទាន់បានអនុវត្តនៅឡើយទេ។ នៅក្នុងករណីផ្សេងទៀត ជនជាប់សង្ស័យត្រូវបានគេចាប់ខ្លួនដោយពុំមានដីកាចាប់ខ្លួននោះឡើយ។

លោកតំណាងពិសេស សូមស្នើអោយអាជ្ញាពាក់ព័ន្ធទាំងអស់ធ្វើការស៊ើបអង្កេតអោយបានហ្មត់ចត់ និងឥតលំអៀង ចំពោះការស្លាប់របស់បុគ្គលដែលមានចុះបញ្ជីនៅទំព័រខាងក្រោយនេះ។ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា មានឆន្ទៈដើម្បីផ្តល់ពតិមានបន្ថែមចំពោះករណីទាំងនេះ។ វាជាការចាំបាច់ណាស់ដែលត្រូវផ្តល់អត្តសញ្ញាណអ្នកទទួលខុសត្រូវ

ទាំងនោះ ហើយនាំខ្លួនពួកគេទៅកាត់ទោស ដោយមិនអោយមានការយឺតយ៉ាវ និងអោយស្របតាមច្បាប់ និងនីតិវិធីព្រហ្មទណ្ឌ។

## ៤. សកម្មជននយោបាយដែលត្រូវបានសំលាប់ចាប់តាំងពីខែមករា ឆ្នាំ២០០១

**ខេត្តបាត់ដំបង**

- សំ សុភា គណបក្ស សម រង្ស៊ី ថ្ងៃទី០៥ ខែវិច្ឆិកា ២០០១
  ស្រុកបាត់ដំបង ឃុំព្រែកព្រះស្តេច ភូមិអូរខ្ចាយ

**ខេត្តកំពង់ចាម**

- ភួង ផាន់ គណបក្ស សម រង្ស៊ី ថ្ងៃទី០៣ ខែមករា ២០០១
  ស្រុកតំបែរ ឃុំទឹកជ្រៅ ភូមិមេសរ
- ឆាយ ថន គណបក្ស ហ្វ៊ុនស៊ីនប៉ិច ថ្ងៃទី១៤ ខែមករា ២០០១
  ស្រុកត្បូងឃ្មុំ ឃុំជីរោទ៍ទី២ ភូមិទួលវិហារ
- ឈឹម លាងស្រ៊ី គណបក្ស សម រង្ស៊ី ថ្ងៃទី២១ ខែកញ្ញា ២០០១
  ស្រុកចំការលើ ឃុំជយោ ភូមិអូរប៉ិច
- ភួង សុផាត គណបក្ស សម រង្ស៊ី ថ្ងៃទី១៤ ខែវិច្ឆិកា ២០០១
  ស្រុកត្បូងឃ្មុំ ឃុំស្រឡប់ ភូមិវាលខ្នាច
- ទូច ផល្លី គណបក្ស ហ្វ៊ុនស៊ីនប៉ិច ថ្ងៃទី១៤ ខែវិច្ឆិកា ២០០១
  ស្រុកត្បូងឃ្មុំ ឃុំស្រឡប់ ភូមិត្រពាំងដំ

**ខេត្តកំពង់ឆ្នាំង**

- មាស សយ គណបក្ស ហ្វ៊ុនស៊ីនប៉ិច ថ្ងៃទី១៧ ខែកក្កដា ២០០១
  ស្រុកសាមគ្គីមានជ័យ ឃុំស្វាយចេក ភូមិត្រពាំងម្ទេស

**ខេត្តកំពង់ស្ពឺ**

- អ៊ុច ហន គណបក្ស សម រង្ស៊ី ថ្ងៃទី៣០ ខែមិថុនា ២០០១
  ស្រុកបសេដ្ឋ ឃុំបសេដ្ឋ ភូមិស្រែព្រោក

**ខេត្តកំពង់ធំ**

- អ៊ុក សៅ  គណបក្ស សម រង្ស៊ី ថ្ងៃទី០៨ ខែធ្នូ ២០០១
  ស្រុកស្ទឹងសែន ឃុំត្បូងក្រពើ ភូមិកល់មេឃ

**ខេត្តកំពត**

- ឡុង គីមថន  គណបក្ស ហ្វ៊ុនស៊ីនប៉ិច ថ្ងៃទី០៤ ខែមករា ២០០២
  ស្រុកជុំគីរី ឃុំជំពូវន្ត ភូមិខ្លី
- សួន គ្រឿន  គណបក្ស ហ្វ៊ុនស៊ីនប៉ិច ថ្ងៃទី០៤ ខែមករា ២០០២
  ស្រុកជុំគីរី ឃុំជំពូវន្ត ភូមិខ្លី

**ខេត្តសៀមរាប**

- ទូច រឿន  គណបក្ស សម រង្ស៊ី ថ្ងៃទី២៣ ខែសីហា ២០០១
  ស្រុកជីក្រែង ឃុំកំពង់ក្ដី ភូមិតាពាម
- រស់ ដន  គណបក្ស ហ្វ៊ុនស៊ីនប៉ិច ថ្ងៃទី១៤ ខែធ្នូ ២០០១
  ស្រុកពួក ឃុំទឹកវិល ភូមិសណ្ដាន់

**ខេត្តស្វាយរៀង**

- ទូច សៀន  គណបក្ស សម រង្ស៊ី ថ្ងៃទី០៥ ខែមករា ២០០២
  ស្រុកស្វាយជ្រុំ ឃុំគោកព្រីង ភូមិដូនលាប

**ខេត្តតាកែវ**

- អ៊ិន ជីលែង  គណបក្ស  ហ្វ៊ុនស៊ីនប៉ិច ថ្ងៃទី១២ ខែធ្នូ ២០០១
  ស្រុកព្រៃកប្បាស ឃុំកំពែង ភូមិកំពែងកណ្ដាល

## ៥.  ការប្រមូលយកប័ណ្ណចុះឈ្មោះបោះឆ្នោត

ដោយសារថា ការចុះឈ្មោះបោះឆ្នោតត្រូវបានចប់នៅខែសីហា ឆ្នាំ២០០១នោះ អាជ្ញាធរមូលដ្ឋាននៅខេត្តផ្សេងៗបានប្រមូលមូលយកវិញនូវប័ណ្ណចុះឈ្មោះបោះឆ្នោតពីអ្នកចុះឈ្មោះបោះឆ្នោត ។ មានករណីជាច្រើនដែលការិយាល័យឧត្ដមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជាបានស៊ើបអង្កេតមកនោះឃើញថា ការប្រមូលយកប័ណ្ណចុះឈ្មោះបោះឆ្នោតវិញ ពីប្រជាជនភាគច្រើននោះ គឺត្រូវបានមេឃុំ មេភូមិ ជាអ្នកបញ្ជាឱ្យធ្វើ ។ មុននិងប្រមូលនោះ គេតែងតែធ្វើបញ្ជីដែលក្នុងនោះមានសរសេរឈ្មោះរបស់អ្នកចុះឈ្មោះបោះឆ្នោត ព្រមទាំងលេខនៃប័ណ្ណបោះឆ្នោតរបស់ពួកគេម្នាក់ៗទៀតផង ។  តាមធម្មតា

តែងតែប្រគល់ប័ណ្ណបោះឆ្នោតនោះមកឱ្យម្ចាស់វិញ ក្នុង ២ ឬ ៣ ថ្ងៃក្រោយមក។ ប៉ុន្តែមានប្រជាជននៅឃុំឈើទាល ព្រែកថ្មី និងសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល បានរាយការណ៍មកថា ប័ណ្ណបោះឆ្នោត ដែលគេបានដកហូតទុកនៅខែសីហា គឺបន្ទាប់ពីបានចុះឈ្មោះហើយភ្លាមនោះ មកទល់ចុងខែធ្នូហើយក៏នៅតែមិនទាន់បានយកមកឱ្យវិញនៅឡើយទេ។

ក្នុងករណីជាច្រើន អាជ្ញាធរមិនដែលបានពន្យល់ឱ្យបានច្បាស់ថាហេតុអ្វីបានជាពួកលោកដើរប្រមូលប័ណ្ណចុះឈ្មោះឆ្នោតទាំងនោះឡើយ។ មានរឿងផ្សេងៗទៀត ដែលប្រជាជននិយាយថាការដើរប្រមូលយកប័ណ្ណបោះឆ្នោតបែបនេះ គឺគេធ្វើឡើងដើម្បីការពារកុំឱ្យមានការបន្លំការបោះឆ្នោត។ រីឯច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ បានហាមប្រាមមិនអោយជនណាម្នាក់រឹបអូសយកប័ណ្ណបោះឆ្នោតឡើយ។ មាត្រាទី ២៣១នៃច្បាប់នេះចែងថា ជនណាម្នាក់ដែលបានរឹបអូសប័ណ្ណចុះឈ្មោះបោះឆ្នោត ឬវិញ្ញាបនប័ត្រជំនួសប័ណ្ណបោះឆ្នោតពីជនណាម្នាក់នោះ ជននោះឯងនឹងត្រូវគេប្តឹងអោយគណៈកម្មាធិការរៀបចំការបោះឆ្នោតដកហូតប័ណ្ណចុះឈ្មោះបោះឆ្នោតរបស់ខ្លួនភ្លាម ហើយត្រូវបង់ប្រាក់ពិន័យចំនួនពី ៥ ទៅ ២៥ លានរៀលទៀតផង។ ប្រសិនបើជនដែលជាអ្នកដកហូតប័ណ្ណចុះឈ្មោះបោះឆ្នោតនោះ ជាបេក្ខជនឈរឈ្មោះបោះឆ្នោតទៀតនោះ គណៈកម្មាធិការរៀបចំការបោះឆ្នោតត្រូវតែលុបឈ្មោះរបស់បេក្ខជននេះចេញពីបញ្ជីបេក្ខជន ហើយដោយសារតែការប្រព្រឹត្តនេះ គាត់ពិតជានឹងត្រូវហាមមិនឱ្យឈរឈ្មោះជាបេក្ខជនបោះឆ្នោតទៀតផង។ មន្ត្រីដែលជាអ្នកទទួលខុសត្រូវក្នុងការប្រមូលយកប័ណ្ណបោះឆ្នោតនេះ ភាគច្រើនគឺជាបេក្ខជនឈរឈ្មោះបោះឆ្នោតខាងគណបក្សប្រជាជន។

ការប្រមូលយកប័ណ្ណចុះឈ្មោះបោះឆ្នោត (ប្រៀបបានទើងការបំភិតបំភ័យក៏វិទាប) ពិតជាអាចនឹងបង្កើននូវផលវិបាកនៃបំភិតពំភ័យមួយយ៉ាងខ្លាំងទៅលើបរិយាកាសបោះឆ្នោតនៅកម្ពុជា ដែលគ្មានស្ថេរភាពស្រាប់ទៅហើយនោះ។ បញ្ហានេះរឹតតែមានការពិតណាស់ទៅទៀត នៅក្នុងសង្កាត់ និងកន្លែងណាដែលសហគមន៍នានា កំពុងត្រូវបានស្ថិតនៅក្រោមអំពើហឹង្សា និងការគំរាមគំហែងស្រេចហើយនោះ។ ការខំប្រឹងប្រែងខាងការអប់រំស្តីពីការបោះឆ្នោតនេះ គួរតែត្រូវបានគេផ្តោតផ្ចិតផ្ចង់ធ្វើឡើងនៅក្នុងកន្លែងណាដែលកំពុងមានវិបត្តិនេះ ដើម្បីធ្វើយ៉ាងណាឱ្យអំពើខុសច្បាប់បែបនេះលែងមានតទៅទៀតដើម្បីកុំឱ្យមានផលប៉ះពាល់អាក្រក់ដល់លទ្ធផលនៃការបោះឆ្នោតលើកនេះ។

នៅថ្ងៃទី ២ ខែវិច្ឆិកា ឆ្នាំ២០០១ លោកសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានចេញបទបញ្ជា ទៅលោកអភិបាលខេត្តបាត់ដំបង ពោធិសាត់ សៀមរាប កំពត តាកែវ កំពង់ស្ពឺ និងព្រៃវែង ដើម្បីឱ្យធ្វើការស៊ើបអង្កេតទៅលើការប្រមូលយកប័ណ្ណចុះឈ្មោះបោះឆ្នោតនេះ ។ ក្នុងខណៈដែលក្រសួងមហាផ្ទៃបានចេញជាបទបញ្ជាបែបនេះនោះ ខាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតគ្មានបានចាត់វិធានការណ៍ណាមួយទាល់តែសោះ ដើម្បីធានាឱ្យមានការពង្រឹង ការអនុវត្តឱ្យបានត្រឹមត្រូវនូវមាត្រា ២៣១ នៃច្បាប់នេះ ។

## ៦. ការអនុវត្តច្បាប់

នៅថ្ងៃទី ១២ ខែតុលា ឆ្នាំ ២០០១ តុលាការខេត្តកំពង់ស្ពឺ បានជំនុំជំរះ ហើយកាត់ទោសដាក់ពន្ធនាគារមនុស្ស២នាក់ពីបទមនុស្សឃាត និងការឃុបឃិតគ្នាធ្វើមនុស្សឃាត ចំពោះសកម្មជនត្រៀមឈរឈ្មោះបោះឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់នៃគណបក្ស សម រង្ស៊ី ឈ្មោះលោក អ៊ុច-ហាន (សូមមើលនៅផ្នែកនៃការកាប់សម្លាប់) ។ មនុស្សឃាតទាំង ២នាក់នោះ ម្នាក់ត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារ ១៥ឆ្នាំ ហើយម្នាក់ទៀត ១៤ឆ្នាំ ។ នេះ គឺជាវិធានការមួយគួរឱ្យមានមោទនភាព ។ ទោះបីដូច្នោះក៏ដោយ លោកដំណាងពិសេសបានជ្រាបថា នៅក្នុងឆ្នាំ ២០០១ នេះ គឺមិនមានការជំនុំជំរះ និងកាត់ទោសជនណាម្នាក់ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មពាក់ព័ន្ធទៅនឹងការបោះឆ្នោតនេះនៅឡើយទេ ថ្វីបើមានការចាប់បានឧក្រិដ្ឋជន ២-៣ ករណីហើយក៏ដោយ ។

ក្រៅពីបទបញ្ញត្តិជាច្រើនដែលពាក់ព័ន្ធនិងអំពើហឹង្សា ច្បាប់ព្រហ្មទណ្ឌដែលស្ថិតនៅជាធរមាន សព្វថ្ងៃនេះបានអនុញ្ញាតឱ្យដាក់ពន្ធនាគារដល់ទៅ ៣ ឆ្នាំ ចំពោះជនណាដែលបានជ្រៀតជ្រែកចូលក្នុងការប្រើប្រាស់សិទ្ធិបោះឆ្នោតដោយសេរីរបស់អ្នកបោះឆ្នោត ឬបេក្ខជនឈរឈ្មោះឱ្យគេបោះឆ្នោតឱ្យ ឬក៏ក្នុងដំណើរការប្រព្រឹត្តទៅនៃការបោះឆ្នោត [៦] ។

ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ក៏បានបញ្ចូលនូវផ្នែកការផ្តន្ទាទោសដោយទូលំទូលាយផងដែរ ។ ជំពូក ១៦ នៃច្បាប់នេះ មានដាក់ចូលនូវបទបញ្ញត្តិនានាស្តីពីការប្រព្រឹត្តដែលធ្វើឡើងដោយមន្ត្រីបោះឆ្នោត ក៏ដូចជាដោយពលរដ្ឋសាមញ្ញដែរ ។ ក្នុងចំណោមការប្រព្រឹត្តិដែល

---

[៦]- បទបញ្ញត្តិស្តីពី តុលាការនិង ក្រមព្រហ្មទ័ណ្ឌ ព្រមទាំងនីតិព្រហ្មទ័ណ្ឌ ដែលប្រើប្រាសនៅកម្ពុជា សម័យអន្តរកាល មាត្រា ៦៤ ។

ត្រូវហាមនោះគឺមានការដកហូតយកប័ណ្ណចុះឈ្មោះបោះឆ្នោតពីជនណាម្នាក់ ការចូលទៅក្នុងមណ្ឌលចុះឈ្មោះបោះឆ្នោត ឬមណ្ឌលបោះឆ្នោតដោយគ្មានការអនុញ្ញាត ការប្រើកម្លាំង ឬការបំភិតបំភ័យដើម្បីបង្កើតឱ្យមានការបាត់បង់ការទុកចិត្តចំពោះការរក្សាការសម្ងាត់ក្នុងការបោះឆ្នោត ការទិញសន្លឹកឆ្នោត ការដាក់កំហិតអ្នកបោះឆ្នោតឱ្យធ្វើសម្បថដើម្បីគាំទ្រដល់គណបក្សខ្លួន ការគំរាមគំហែង និងការបំភិតពំភ័យ ដើម្បីកុំឱ្យអ្នកណាម្នាក់ហ៊ានឈរឈ្មោះជាបេក្ខជន ហើយរារាំងមិនឱ្យគណបក្សនយោបាយព្រមទាំងសមាជិករបស់គេធ្វើសកម្មភាពយុទ្ធនាការឃោសនាបោះឆ្នោត ។

បទបញ្ញត្តិអស់ទាំងនេះ  បានតម្រូវឱ្យមានការផាកពិន័យ ការដកហូតយកវិញនូវប័ណ្ណចុះឈ្មោះបោះឆ្នោត ការរឹបអូសយកវត្ថុ និងសារជាតិដែលប្រកបដោយគ្រោះថ្នាក់ ហើយបើសិនជាអ្នកប្រព្រឹត្តអំពើនេះជាបេក្ខជនឈរឈ្មោះបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់នោះ គេនឹងត្រូវបានហាមមិនឱ្យឈរឈ្មោះបោះឆ្នោតទេ ។ បន្ថែមទៅលើការដាក់ទណ្ឌកម្មនេះ មន្ត្រីខាងរដ្ឋបាលទទួលបន្ទុកការបោះឆ្នោតអាចត្រូវបានថ្នាក់លើស្តីបន្ទោស ព្រមទាំងដកចេញពីការការទៀតផង ។

ក្នុងដំណាច់ខែ វិច្ឆិកា ឆ្នាំ ២០០១  គជប  បានចេញបទបញ្ជាមួយស្តីពីនីតិវិធីសវនាការទៅលើការរំលោភច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ។ បទបញ្ជានេះ ព្រមទាំងបទបញ្ជាផ្សេងៗនានាដែល គជប បានអនុម័តពីមុនហើយ បានថ្លែងបញ្ជាក់ថា *រដ្ឋបាលទទួលបន្ទុកការបោះឆ្នោតមានអំណាចបើកសវនាការ ព្រមទាំងបញ្ជាឱ្យផាកពិន័យ អ្នកណាដែលបានប្រព្រឹត្តជាការល្មើសនឹងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ។* ថ្វីបើការរំលោភច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ជាច្រើនត្រូវបានគេប្រព្រឹត្តឡើង ហើយត្រូវបានរាយការណ៍ជូនទៅ គជប អោយបានជ្រាបហើយក៏ដោយ គឺគ្មានអ្នកប្រព្រឹត្តខុសណាម្នាក់ត្រូវបានគេដាក់ទណ្ឌកម្មនោះឡើយ ។

ដូច្នេះ យើងសូមធ្វើអនុសាសន៍ថា សូមឱ្យភ្នាក់ងារប្រតិបត្តិច្បាប់ទាំងឡាយ និង គ.ជ.ប. ចាត់វិធានការណ៍ស៊ើបអង្កេតឱ្យបានឆាប់បំផុត នូវរាល់ឧក្រិដ្ឋកម្មដែលគួរឱ្យសង្ស័យផ្សេងៗ និងអំពើដទៃទៀត ដែលចាត់ទុកថាវាខុសនឹងច្បាប់ស្តីពីការបោះឆ្នោតក្រុមប្រឹក្សាប្រឹក្សាឃុំ-សង្កាត់ ។ វាជាការចាំបាច់ណាស់ដែលត្រូវតែចាប់ជនណាដែលជាអ្នកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម អស់នោះបញ្ជូនទៅតុលាការ ហើយការផ្តន្ទាទោសត្រូវតែធ្វើឡើងចំពោះករណីទាំងអស់ដែលបានរកឃើញថា អំពើខុសច្បាប់ពិតជាត្រូវបានគេប្រព្រឹត្តមែន ។

## ៧. សេចក្ដីសន្និដ្ឋាន និងអនុសាសន៍

ប្រភេទដូចគ្នានៃឧក្រិដ្ឋកម្ម និងការអនុវត្តន៍ដោយមិនត្រឹមត្រូវតាមច្បាប់ជាច្រើន ដែលបានសង្កេតឃើញនៅក្នុងការបោះឆ្នោតជាសាកលក្នុងឆ្នាំ១៩៩៨ កំពុងត្រូវបានកើតមានជាថ្មីឡើងវិញនៅក្នុងរយៈពេលឆ្ពោះទៅរកការបោះឆ្នោតឃុំនៅខែកុម្ភៈខាងមុខនេះ ។ ទាំងនេះ រួមមានឃាតកម្ម ការគំរាមកំហែងដល់អាយុជីវិត ការចាប់ខ្លួនដោយខុសច្បាប់ ការរំលោភលើរាងកាយ ការរៀបចំពិធីដែលក្នុងនោះប្រជាពលរដ្ឋត្រូវបានស្នើ អោយស្បថដើម្បីគាំទ្រគណបក្សកាន់អំណាច ការរឹបអូសយកបណ្ណ័បោះឆ្នោត និងការបំផ្លាញទ្រព្យសម្បត្តិរបស់គណបក្ស ។ បញ្ហាទាំងនេះមានភាពធ្ងន់ស្រាលខុសគ្នាពីតំបន់មួយទៅតំបន់មួយ ប៉ុន្តែជាទូទៅវាហាក់ដូចជាកើតឡើងនៅក្នុងកំរិតដូចគ្នាក្នុងឆ្នាំ១៩៩៨ ដែរ ។ ហេតុដូច្នេះវានាំអោយមានការព្រួយបារម្ភ ថាបញ្ហាទាំងឡាយដូចនេះ កំពុងតែចាក់ឫសជាការធម្មតាមួយនៃដំណើរការបោះឆ្នោតនៅកម្ពុជា ។ ដោយយោងទៅលើបញ្ហានេះ លោកតំណាងពិសេសសូមផ្ដល់អនុសាសន៏ដូចតទៅនេះ :

- គួរចាត់វិធានការបន្ទាន់នានា ដើម្បីធានាថាសកម្មជនគណបក្ស និងក្រុមគ្រួសាររបស់ពួកគេត្រូវបានការពារដោយសមរម្យពីការបង្ករបួសស្នាម ឬការជ្រៀតជ្រែកណាមួយ ។
- គួរធ្វើការស៊ើបអង្កេតជាបន្ទាន់ និងអោយគ្រប់ជ្រុងជ្រោយពីការចោទប្រកាន់លើអំពើហិង្សា និងការបំភិតបំភ័យទាំងឡាយប្រឆាំងនឹងសមាជិកគណបក្សនយោបាយ ។
- គួរចាត់ឡើងនូវជំហានឆាប់រហ័ស និងប្រកបដោយប្រសិទ្ធិភាព ដើម្បីដោះស្រាយបញ្ហានីទណ្ឌភាព និងការរំលោភច្បាប់នៅក្នុងខេត្តកំពង់ចាម និងកំពត ដោយយកចិត្តទុកដាក់ជាពិសេសចំពោះបញ្ហាទាំងឡាយដែលបានរកឃើញនៅក្នុងស្រុកត្បូងឃ្មុំ និងស្រុកឈូក ក៏ដូចជានៅក្នុងតំបន់ជុំវិញផងដែរ ។
- គួរចាត់វិធានការភ្លាមៗដើម្បីអនុវត្តបទបញ្ញត្តិដែលមានក្នុងច្បាប់ព្រហ្មទណ្ឌ និងច្បាប់បោះឆ្នោត ។
- គួរបង្កើនការអប់រំអ្នកបោះឆ្នោតជាពិសេសនៅក្នុងស្រុកទាំងឡាយណា ដែលមានបញ្ហាកើតឡើង ។
- គួរចេញបទបញ្ជាអោយច្បាស់លាស់មួយទៅកងយុទ្ធពលខេមរៈភូមិន្ទថា ជនសង្ស័យទាំងឡាយដែលពាក់ពន្ធ័នឹងករណីរំលោភច្បាប់ព្រហ្មទណ្ឌ័ និងច្បាប់បោះឆ្នោតឃុំ-



នេះជាការបកប្រែពីអត្ថបទដើមដែលជាភាសាអង់គ្លេស

សង្កាត់ នឹងមិនត្រូវបានការពារអោយរួចផុតពីការចាប់ខ្លួន ឬដំណើរការក្តីតាមផ្លូវតុលាការនោះឡើយ ។

- គួរធ្វើការរំលឹកអោយបានច្បាស់លាស់ថែមទៀតដល់អាជ្ញាធរពាក់ព័ន្ធ និងសាធារណៈជនថា អំពើហិង្សា និងការបំភិតបំភ័យប្រឆាំងសមាជិកនៃគណបក្សនយោបាយ នឹងមិនត្រូវបានអត់អោនអោយឡើយ នៅមុន កំឡុងពេល ឬក្រោយរយៈពេលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ និងរយៈពេលដែលនឹងដឹកនាំឆ្ពោះទៅរកការបោះឆ្នោតសភាជាតិនៅឆ្នាំ ២០០៣ ។
- គួរមានការចាត់វិធានការជាបន្ទាន់ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីធានាថា អង្គភាពផ្នែកស៊ើបអង្កេតរបស់ខ្លួន ធ្វើការពិនិត្យមើល និងស៊ើបអង្កេតប្រកបដោយប្រសិទ្ធិភាព និងគ្រប់ជ្រុយជ្រោយលើពាក្យបណ្តឹង ដែលខ្លួនបានទទួល ។

COHCHR 11 January 2001